# ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុនផាក

CAMPU LONPAC INSURANCE 柬埔寨大众伦平保险

## យើងខ្ញុំធានារ៉ាប់រងលោកអ្នក ក្នុងប្រទេសកម្ពុជា

កិច្ចសន្យាធានារ៉ាប់រងលើការទទួលខុសត្រូវជាសាធារណៈ

ប្រសិនបើលោកអ្នកមិនពេញចិត្តនឹងសេវាកម្មរបស់ក្រុមហ៊ុនយើងខ្ញុំ សូមមេត្តាសរសេរលិខិតមកក្រុមទទួលពាក្យបណ្តឹងរបស់យើងខ្ញុំ:

| | | |
|---|---|---|
| អាសយដ្ឋានទំនាក់ទំនង : | | **ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុនប៉ាក ភីអិលស៊ី** |
| | | ជាន់ទី៧ នៃអគារកម្ពុប៊ែង |
| | | ផ្ទះលេខ ២៣ ផ្លូវ ១១៤ |
| | | សង្កាត់ផ្សារថ្មី ២ |
| | | ខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| | | ព្រះរាជាណាចក្រកម្ពុជា |
| | | ប្រអប់សំបុត្រ ១៥៥៦ |
| លេខទូរស័ព្ទ | : | + ៨៥៥ ២៣ ៩៦៦ ៩៦៦/ ៩៩៨ ២០០/ ៩៨៦ ២៧៩ |
| លេខទូរសារ | : | + ៨៥៥ ២៣ ៩៨១ ៣០៨/ ២៧៣ |
| អ៊ីម៉ែល | : | + complaint@campulonpac.com.kh |
| គេហទំព័រ | : | www.campulonpac.com.kh |

**ក្នុងករណីមានឧប្បត្តិហេតុកើតឡើង**

**លេខទូរស័ព្ទប្រចាំការ២៤ម៉ោង**

+ ៨៥៥ ១៦ ៨១៩ ៩៩៩/ ៨២០ ៩៩៩

+ ៨៥៥ ១៧ ៧៩៩ ៩០២/ ៧៩៩ ៩០៣

អ៊ីម៉ែល : claims@campulonpac.com.kh

<u>សំគាល់:</u>

ក្នុងករណីមានវិវាទកើតឡើង ឬការខុសឆ្គងអត្ថន័យណាមួយនៅក្នុងកិច្ចសន្យាធានារ៉ាប់រងជាភាសាខ្មែរ នោះក្រុមហ៊ុនធានារ៉ាប់រងយើងខ្ញុំនឹងយកកិច្ចសន្យាធានារ៉ាប់រងជាភាសាអង់គ្លេសជាសំអាង។ យើងខ្ញុំសូមស្នើរជាពិសេសថា សូមលោកអ្នកអានកិច្ចសន្យាធានារ៉ាប់រងនេះអោយបានហ្មត់ចត់និងផ្ញើត្រឡប់មកកាន់ក្រុមហ៊ុនយើងខ្ញុំវិញភ្លាមប្រសិនបើមានភាពចាំបាច់ត្រូវកែតម្រូវ។

## កិច្ចសន្យាធានារ៉ាប់រងលើការទទួលខុសត្រូវជាសាធារណៈ

**ដោយហេតុថា** បុគ្គលដែលត្រូវបានការធានារ៉ាប់រង តាមរយៈសំណើដែលជាមូលដ្ឋាននៃកិច្ចសន្យានេះ ព្រមទាំងបានដាក់ពាក្យសុំទៅក្រុមហ៊ុនខាងលើ (តទៅនេះហៅកាត់ថា "ក្រុមហ៊ុន") ដើម្បីទាមទារសំណងដែលបានបញ្ជាក់ជូនដូចខាងក្រោម និងបានបង់ឬយល់ព្រមបង់បុព្វលាភធានារ៉ាប់រងជាថ្នូរនឹងឬដើម្បីទទួលបានសំណងទាំងនោះ។

**កិច្ចសន្យាធានារ៉ាប់រងនេះបញ្ជាក់ថា** ដោយយោងទៅតាម ខ ចែង ករណីលើកលែង ដែនកំណត់ និងលក្ខខណ្ឌដែលមានចែង ឬ យល់ព្រមនៅក្នុងកិច្ចសន្យានេះ ក្រុមហ៊ុននឹងធ្វើសំណងជូនបុគ្គលដែលត្រូវបានធានារ៉ាប់រងនូវ

(ក) ចំនួនទឹកប្រាក់ទាំងអស់ ដែលបុគ្គលត្រូវធានារ៉ាប់រងត្រូវទទួលខុសត្រូវស្របច្បាប់ចំពោះសំណងដែលទាក់ទិននឹង

១. របួសលើរាងកាយរបស់បុគ្គលណាម្នាក់

២. ការបាត់បង់ ឬការខូចខាតទ្រព្យសម្បត្តិដែលកើតឡើងក្នុងបរិវេណដែលបានកំណត់ ក្នុងអំឡុងពេលនៃការធានារ៉ាប់រង ដែលជាលទ្ធផលបណ្តាលមកពីគ្រោះថ្នាក់ និងដែលកើតឡើង ឬបង្កឡើងដោយជាប់ពាក់ព័ន្ធនឹងអាជីវកម្មរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ដូចមានរៀបរាប់នៅក្នុងតារាងឧបសម្ព័ន្ធ។

(ខ) រាល់ថ្លៃ និងចំណាយផ្សេងៗលើការជម្រះក្តី

១. ដែលបានទាមទារដោយអ្នកមានសិទ្ធិទារសំណងណាម្នាក់ ពីបុគ្គលដែលត្រូវបានធានារ៉ាប់រង

២. ដែលបានកើតឡើងដោយមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីក្រុមហ៊ុនដែលពាក់ព័ន្ធនឹងបណ្តឹងទាមទារសំណងពីបុគ្គលដែលត្រូវបានធានារ៉ាប់រងចំពោះសំណងដែលបានបញ្ជាក់នៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ ។

ការទទួលខុសត្រូវរបស់ក្រុមហ៊ុនចំពោះការខូចខាត និងថ្លៃព្រមទាំងការចំណាយផ្សេងៗរបស់អ្នកទាមទារសំណង ទាក់ទិននឹងការទាមទារមួយ ឬទាំងអស់បន្តបន្ទាប់គ្នា (ទោះជាកើតឡើងនៅក្នុងរយៈពេលនៃការធានារ៉ាប់រងណាមួយ ឬអត់ក៏ដោយ) ដែលកើតឡើងពី ឬបង្កឡើងដោយប្រភពឬដើមហេតុដំបូងណាមួយ នឹងមិនត្រូវលើសពីដែនកំណត់នៃការធ្វើសំណងឡើយ។

ក្នុងករណីបុគ្គលដែលត្រូវបានធានារ៉ាប់រងទទួលមរណភាព ទាក់ទិននឹងការទទួលខុសត្រូវដែលរ៉ាប់រងដោយបុគ្គលដែលត្រូវបានធានារ៉ាប់រងក្រុមហ៊ុន នឹងធ្វើសំណងជូនតំណាងផ្ទាល់ខ្លួនរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង តាមលក្ខខណ្ឌ និងដោយផ្អែកលើដែនកំណត់នៃកិច្ចសន្យាធានារ៉ាប់រងនេះ ប្រសិនបើតំណាងផ្ទាល់ខ្លួនរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រងទាំងនោះ គោរព និងអនុវត្តតាមករណីលើកលែង និងលក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ ក្នុងកម្រិតដែលពួកគេអាចអនុវត្តបានប្រៀបដូចជាបុគ្គលដែលត្រូវបានធានារ៉ាបរងផងដែរ។

## ករណីលើកលែង

(ក) សំណងដែលបង្ហាញនៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះមិនអនុវត្តចំពោះ :

១. ការទទួលខុសត្រូវទាក់ទិននឹងរបួសស្នាម ជំងឺ ការបាត់បង់ ឬការខូចខាតដែលបណ្តាលមកពីទង្វើ ឬការធ្វេសប្រហែសដោយចេតនារបស់បុគ្គលដែលត្រូវបានធានារ៉ាប់រងហើយដែលអាចត្រូវបានរំពឹងទុកយ៉ាងសមហេតុផលថាមានទាក់ទិននឹងសភាព និងស្ថានភាពនៃទង្វើ ឬការធ្វេសប្រហែសទាំងនោះ។

២. ការទទួលខុសត្រូវដែលត្រូវបានសន្មត់ដោយបុគ្គលដែលត្រូវបានធានារ៉ាប់រងតាមរយៈការព្រមព្រៀង ហើយដែលមិនជាប់កាតព្វកិច្ចក្នុងករណីគ្មានការព្រមព្រៀងនោះ

៣. ការទទួលខុសត្រូវក្នុងករណី

(ក) របួសលើរាងកាយរបស់បុគ្គលណាម្នាក់ ដែលស្ថិតនៅក្នុងកិច្ចសន្យាផ្តល់សេវា ឬហ្វឹកហ្វឺនជាកូនជាងជាមួយបុគ្គលដែលត្រូវបានធានារ៉ាប់រង ប្រសិនបើការទទួលខុសត្រូវទាំងនោះទាក់ទិននឹងរបួសលើរាងកាយ កើតចេញពីនិងនៅហេតុផល នៃការបម្រើការងាររបស់បុគ្គលទាំងនោះចំពោះបុគ្គលដែលត្រូវ បានធានារ៉ាប់រង ឬចំពោះសមាជិកណាម្នាក់នៃគ្រួសារ របស់បុគ្គលដែលត្រូវបានធានារ៉ាប់រង

(ខ) ចំនួនទឹកប្រាក់ដែលត្រូវបង់ដោយបុគ្គលដែលត្រូវបានធានារ៉ាប់រងដោយយោងតាមច្បាប់ និង/ ឬ បទប្បញ្ញត្តិដែលទាក់ទិននឹងរបួសលើរាងកាយក្នុងពេលបំពេញការងារ

៤. ការទទួលខុសត្រូវទាក់ទិននឹងការបាត់បង់ ឬការខូចខាតទ្រព្យសម្បត្តិ

(ក) ដែលជាកម្មសិទ្ធិរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង

(ខ) ដែលជាបន្ទុក ឬស្ថិតក្រោមការគ្រប់គ្រងរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ឬអ្នកផ្តល់សេវា ឬភ្នាក់ងារណាមួយ ឬសមាជិកណាម្នាក់នៃគ្រួសាររបស់បុគ្គលដែលត្រូវបានធានរ៉ាប់រង

(គ) ដែលផ្នែកនៃទ្រព្យសម្បត្តិណាមួយ ត្រូវបានបុគ្គលដែលត្រូវបានធានារ៉ាប់រង ឬអ្នកផ្តល់សេវា ឬភ្នាក់ងាររបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង កំពុង ឬបានប្រើប្រាស់ ប្រសិនបើការបាត់បង់ ឬការខូចខាតនោះកើតឡើង ដោយផ្ទាល់ពីការប្រើប្រាស់នោះ

(ឃ) ដែលបង្កឡើងដោយ ឬទាក់ទិននឹង ឬដែលកើតឡើងពីការផ្ទុះនូវផ្នែកសម្ពាធណាមួយនៃ

(i) ប្រព័ន្ធចំហាយទឹកក្តៅ (Steam Boiler) ឬប្រព័ន្ធផ្លាស់ប្តូរកម្តៅ (Economizer)

(ii) កប៉ាល់ ឬឧបករណ៍ណាមួយ (ផ្សេងពីប្រព័ន្ធកម្តៅទួរប៊ីន ឬម៉ាស៊ីន ឬម៉ាស៊ីនប្រើចំហាយ ផ្សេងទៀត) ដែលធ្វើប្រតិបត្តិការដោយប្រព័ន្ធសម្ពាធចំហាយទឹកដែលជាកម្មសិទ្ធិរបស់ ឬស្ថិតក្រោមការគ្រប់គ្រងរបស់បុគ្គលដែលត្រូវធានារ៉ាប់រង ឬអ្នកផ្តល់សេវា ឬភ្នាក់ងារណាម្នាក់របស់បុគ្គលដែលត្រូវបានធានារ៉ាប់រង

៥. ការទទួលខុសត្រូវទាក់ទិននឹង

(ក) ការបាត់បង់ ឬការខូចខាតទ្រព្យសម្បត្តិ ឬដីធ្លី ឬអគារណាមួយដែលបង្កឡើងដោយរំញ័រ ឬដោយការបើចេញ ឬភាពមិនរឹងមាំនៃគ្រោងអគារ

(ខ) របួសលើរាងកាយរបស់បុគ្គលណាម្នាក់ ឬការបាត់បង់ ឬការខូចខាតទ្រព្យសម្បត្តិដែលបង្កឡើងដោយសារការបាត់បង់ ឬការខូចខាតដែលបានលើកឡើងខាងលើ

៦. ការទទួលខុសត្រូវទាក់ទិននឹងរបួសស្នាមលើរាងកាយ ការបាត់បង់ ឬការខូចខាតទ្រព្យសម្បត្តិដែលបង្កឡើងដោយ ឬទាក់ទងនឹង ឬកើតឡើងពី:

(ក) យានយន្តដែលដំណើរការដោយប្រព័ន្ធមេកានិច ដែលមានអាជ្ញាប័ណ្ណសម្រាប់ប្រើប្រាស់លើផ្លូវដែលជាកម្មសិទ្ធិ ឬកាន់កាប់ ឬប្រើប្រាស់ដោយ ឬក្នុងនាមបុគ្គលដែលត្រូវបានធានារ៉ាប់រង

(ខ) កប៉ាល់ទឹក ឬយន្តហោះ (ផ្សេងពីទូក ឬក្បូនដែលទៅមុខដោយប្រើដៃ) ដែលបង្កើតឡើង ឬគ្រោងធ្វើដំណើរតាមផ្លូវទឹក ឬផ្លូវអាកាស ឬក្បាលអូសស្វ័យយាន យានយន្តណាមួយ (ឬយានយន្តសណ្តោងដែល) ភ្ជាប់នឹងយានយន្តទាំងនោះ ឬសត្វពាហនៈដែលជាកម្មសិទ្ធិ ឬកាន់កាប់ ឬប្រើប្រាស់ ដោយឬក្នុងនាម បុគ្គលដែលត្រូវបានធានារ៉ាប់រង ឬការលើកឡើង ឬដាក់ចុះទំនិញ ពីយានយន្តទាំងនោះ

(គ) ភាពជាកម្មសិទ្ធិ ឬប្រតិបត្តិការអាកាសយានដ្ឋាន ឬវាលយន្តហោះ (សម្រាប់ចុះចតនៅពេលមានអាសន្ន)

(ឃ) ជណ្តើរស្ទូច ជណ្តើរយោង ជណ្តើរយន្ត គ្រឿងស្ទូច ឬប្រដាប់ស្ទូចដែលជាកម្មសិទ្ធិ ឬប្រើប្រាស់ ដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ឬក្នុងការថែទាំដែលបុគ្គលត្រូវបានធានារ៉ាប់រង ត្រូវទទួលខុសត្រូវ

(ង) ការរៀបចំផ្នែកអនាម័យមានការខ្វះចន្លោះ ឬការបំពុលគ្រប់ប្រភេទ

(ច) អាហារ ឬភេសជ្ជៈ ឬសារធាតុចម្លែក ឬមានគ្រោះថ្នាក់នៅក្នុងអាហារ ឬភេសជ្ជៈដែលបានលក់ ឬផ្គត់ផ្គង់ ឬផ្តល់ ឬប្រគល់ ឬចែកចាយដោយ ឬក្នុងនាមបុគ្គលដែលត្រូវបានធានារ៉ាប់រង

(ឆ) របស់របរ ឬទំនិញ ឬផលិតផល ឬវត្ថុ ឬឧបករណ៍ស្តុក ដែលបានលក់ ឬផ្គត់ផ្គង់ ឬចែកចាយ ឬផ្តល់សេវា ឬជួសជុល ឬកែលម្អ ឬផ្លាស់ប្តូរ ឬប្រព្រឹត្តិកម្ម ឬកែច្នៃ ឬសាងសង់ ឬផលិត ឬដំឡើង ឬដាក់ជួល ឬ ចាត់ចែងដោយ ឬក្នុងនាម បុគ្គលដែលត្រូវបានធានារ៉ាប់រង

(ជ) អគ្គិភ័យ ការផ្ទុះនានា ទឹកជំនន់ រញ្ជួយដី ការផ្ទុះភ្នំភ្លើង ខ្យល់ព្យុះ ព្យុះកំបុតត្បូង ព្យុះសង្ឃរា ខ្យល់គួច ឬ ការរំខានពីបរិយាកាស ឬបាតុភូតធម្មជាតិផ្សេងទៀត

(ឈ) ការភាន់ច្រលំ ការភ្លេចភ្លាំង ឬការធ្វេសប្រហែសនៅក្នុងប្លង់ គំនូរ លក្ខណៈបច្ចេកទេស រូបមន្ត ឬដំបូន្មាន ឬឯកសារខុសឆ្គង

(ញ) ដំបូន្មានមានលក្ខណៈដំណោះស្រាយវិជ្ជាជីវៈ ឬដំបូន្មានផ្សេងទៀត ឬការពិនិត្យដែលបានផ្តល់ ឬគ្រប់គ្រង ដែលមានការភ្លេចភ្លាំង ឬរៀបចំឡើងដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ឬបុគ្គលណាមួយដែលធ្វើសកម្មភាព ក្នុងនាមបុគ្គលដែលត្រូវបានធានារ៉ាប់រង

(ដ) គ្រោះថ្នាក់ចំពោះកប៉ាល់ ឬនាវាដែលជាលទ្ធផលនៃលក្ខខណ្ឌមិនសមស្របនៃផែ កំពង់ផែ ឬកន្លែងចត

(ឋ) ការសាងសង់ និងការថែទាំទំនប់

(ឌ) ការផលិត និងការផ្ទុកគ្រឿងផ្ទុះ

(ឍ) ការជីករ៉ែ ការកែច្នៃ ការផលិត ការចែកចាយ និង/ឬការផ្ទុកសារធាតុដែលដុតមិនឆេះ និង/ឬ ផលិតផលដែលធ្វើឡើងទាំងស្រុងពីសារធាតុដែលដុតមិនឆេះ ឬការបើចេញ និង/ឬការដឹកជញ្ជូនសារធាតុ ដែលដុតមិនឆេះទាំងនោះ

(ណ) ជំងឺឆ្លង ឬជំងឺរាតត្បាត

៧. ការទទួលខុសត្រូវចំពោះផលវិបាកនៃសង្គ្រាម ការឈ្លានពាន សកម្មភាពរបស់សត្រូវបរទេស អំពើបង្កសង្គ្រាម (ទោះបីជាសង្គ្រាមត្រូវបានប្រកាស ឬអត់ក៏ដោយ) សង្គ្រាមស៊ីវិល អំពើឧទ្ទាម សង្កុបកម្ម បដិវត្តន៍ អំពើបះបោរ អំណាចយោធា ឬការដណ្តើមអំណាច ក្បត់កម្ម កុបកម្ម ឬអំពើចលាចលរបស់ប្រជាជន

៨. (ក) ការទទួលខុសត្រូវផ្លូវច្បាប់គ្រប់ប្រភេទ ដែលបង្កឡើងដោយផ្ទាល់ ឬដោយប្រយោលដែលបណ្តាលមកពី ឬរួមចំណែកដោយ ឬកើតឡើងពីការភាយ ឬការបំភាយនៃសារធាតុវិទ្យុសកម្ម ឬពីកាកសំណល់នុយក្លេអ៊ែរ ឬពីចំហេះនៃឥន្ធនៈនុយក្លេអ៊ែរ ។ សម្រាប់គោលបំណងតែមួយគត់

នៃករណីលើកលែងនេះ ចំហេះត្រូវកើតឡើងពីដំណើរការទ្រទ្រង់បន្ទុះដោយខ្លួនឯងនៃសារធាតុនុយក្លេអ៊ែរ។

(ខ) គ្រោះថ្នាក់ការបាត់បង់ ការបំផ្លាញ ការខូចខាត ឬការទទួលខុសត្រូវផ្លូវច្បាប់ដែលបង្កឡើងដោយផ្ទាល់ ឬដោយប្រយោលឬដោយរួមចំណែក ឬដោយកើតឡើងពីសព្វាវុធនុយក្លេអ៊ែរ។

៩. ការទទួលខុសត្រូវទាក់ទិននឹងប្រាក់ផាកពិន័យ ប្រាក់ដាក់ទណ្ឌកម្ម ប្រាក់សំណងដើម្បីជាការដាក់ទណ្ឌកម្ម ប្រាក់សំណង ជំងឺចិត្តជាការដាក់ទណ្ឌកម្មប្រាក់សំណងទ្វេមួយជាបី ឬប្រាក់សំណងផ្សេងទៀតដែលកើតឡើងពីប្រាក់សំណងការខូចខាតស្វ័យគុណនៃ ឬលើសពីប្រាក់សំណងលើការខូចខាតធម្មតា។

**(ខ) ខ ចែង ស្តីអំពីករណីលើកលែងលើប្រាក់ផាកពីន័យ ប្រាក់ដាក់ទណ្ឌកម្ម ប្រាក់សំណងដើម្បីជាការដាក់ទណ្ឌកម្ម**

ក្រុមហ៊ុនមិនទទួលខុសត្រូវក្នុងការធ្វើសំណងដល់បុគ្គលដែលត្រូវបានធានារ៉ាប់រង ឬភាគីណាមួយដែលមានឈ្មោះនៅក្នុងកិច្ចសន្យា ធានារ៉ាប់រងនេះ ទាក់ទិននឹងការផាកពិន័យ ឬការដាក់ទណ្ឌកម្មដែលតម្រូវ ឬសំណងដើម្បីជាការដាក់ទណ្ឌកម្ម ឬសំណងជំងឺចិត្ត ជាការដាក់ទណ្ឌកម្មដែលបានសម្រេចជំទាស់ចំពោះបុគ្គលដែលត្រូវបានធានារ៉ាប់រង ឬភាគីណាមួយផ្សេងទៀតដោយតុលាការទោះស្ថិតនៅទីណាក៏ដោយ ។

ក្នុងករណីដែលតុលាការបើកសវនាការដើម្បីកំណត់សំណងការខូចខាត និងសំណងដើម្បីជាការដាក់ទណ្ឌកម្ម ឬសំណងជំងឺចិត្តជាការដាក់ទណ្ឌកម្ម ប្រសិនបើក្រុមហ៊ុនសម្រេចចិត្តការពារក្តី ឬការទាមទារណាមួយ សោហ៊ុយ និងថ្លៃចំណាយផ្លូវច្បាប់ដែលក្រុមហ៊ុនត្រូវទទួលខុសត្រូវ ត្រូវកម្រិតត្រឹមសមាមាត្រនៃសោហ៊ុយ និងថ្លៃចំណាយផ្លូវច្បាប់សរុបដែលទឹកប្រាក់នៃសំណងការខូចខាតដែលបានតម្រូវទូទាត់ជាមួយទឹកប្រាក់សរុបនៃសំណងការខូចខាតដែលបានតម្រូវ និងសំណងជាការដាក់ទណ្ឌកម្ម ឬសំណងជំងឺចិត្តជាការដាក់ទណ្ឌកម្មដែលបានតម្រូវ។

**(គ) ខ ចែងស្តីអំពីករណីលើកលែងចំពោះការបំផ្លាញបរិស្ថានម្តងបន្តិចៗ**

ក្រុមហ៊ុនមិនទទួលខុសត្រូវចំពោះ:

(ក) របួសស្នាមផ្ទាល់ខ្លួន ឬរបួសស្នាមលើរាងកាយ ឬការខាតបង់ផ្នែកហិរញ្ញវត្ថុ ឬការបាត់បង់ ការខូចខាត ឬការបាត់បង់ ការប្រើប្រាស់ទ្រព្យសម្បត្តិដែលកើតឡើងដោយផ្ទាល់ ឬដោយប្រយោលពីការចាក់ចោល ការចោល ការបញ្ចេញ ឬការលេចសារធាតុបំពុល។

(ខ) ថ្លៃចំណាយលើការយកចេញ ការលុបបំបាត់ ឬការសម្អាតសារធាតុបំពុល។

(គ) ប្រាក់ផាកពិន័យ ប្រាក់ទណ្ឌកម្ម ប្រាក់សំណងដើម្បីជាការដាក់ទណ្ឌកម្ម ឬសំណងជំងឺចិត្តជាការដាក់ទណ្ឌកម្ម ដែលកើតឡើងដោយផ្ទាល់ ឬប្រយោលពីការចាក់ចោល ការចោល ការបញ្ចេញ ឬការលេចសារធាតុបំពុល។ ទោះបីជាមានចំណុចដូចបាន រៀបរាប់នៅខាងលើនេះក៏ដោយកិច្ចព្រមព្រៀងនេះនឹងធ្វើសំណងលើការទទួលខុសត្រូវដែលត្រូវបានលើកលែងនៅក្នុងកថាខ័ណ្ឌ (ក) និង (ខ) ខាងលើដែរ

(i) បង្កឡើងដោយឧប្បត្តិហេតុមើលឃើញភ្លាមៗដែលមិនបានព្រៀងទុក និងមិនបានរំពឹងទុកថាកើតឡើងទាំងស្រុងនៅពេលនិងកន្លែងជាក់លាក់ណាមួយ និង

(ii) ត្រូវបានធ្វើសំណងមិនអោយលើសពីមួយដងក្នុងមួយឆ្នាំ ក្នុងអំឡុងពេលនៃការធានារ៉ាប់រងសម្រាប់គោលបំណងនៃ ខ ចែងនេះ ពាក្យថា"សារធាតុបំពុល" សំដៅដល់វត្ថុធ្វើអោយក្រហាយ ឬអង្គធាតុបំភាយរាវ រឹង ឧស្ម័ន ឬ ក្តៅ រួមមានជាអាទិ៍ ផ្សែង ចំហាយ ម្រែងភ្លើង រំភាយ អាស៊ីត អាល់កាលី សារធាតុគីមី និងសំណល់។ សំណល់រួមបញ្ចូល សម្ភារដែលត្រូវធ្វើនិស្សរណកម្ម ផលិតឡើងវិញ ឬយកមកប្រើឡើងវិញ។

**(ឃ) ខ ចែងស្តីអំពីប្រព័ន្ធព័ត៌មានវិទ្យា**

ការខូចខាតទ្រព្យសម្បត្តិដែលត្រូវធ្វើសំណងស្របតាមការធានារ៉ាប់រងនេះ សំដៅដល់ការខូចខាតផ្នែករូបវន្តនៃលក្ខណៈសំខាន់របស់ទ្រព្យសម្បត្តិ។ ការខូចខាតផ្នែករូបវន្តនៃលក្ខណៈសំខាន់របស់ទ្រព្យសម្បត្តិមិនរាប់បញ្ចូលការខូចខាត ទិន្នន័យ ឬកម្មវិធីកុំព្យូទ័រឡើយ ជាពិសេសការផ្លាស់ប្តូរ មិនល្អនៅក្នុងទិន្នន័យ ឬកម្មវិធីកុំព្យូទ័រដែលបង្កឡើងដោយការលុប ការប្រែប្រួល ឬការខូចទ្រង់ទ្រាយ នៃរចនាសម្ព័ន្ធដើម។

ដោយហេតុនេះ ចំណុចខាងក្រោមនេះ ត្រូវបានលើកលែងពីការធានារ៉ាប់រងនេះ :

(ក) ការបាត់បង់ ឬការខូចខាតទិន្នន័យ ឬកម្មវិធីកុំព្យូទ័រ ជាពិសេសការផ្លាស់ប្តូរមិនល្អនៅក្នុងទិន្នន័យ ឬកម្មវិធីកុំព្យូទ័រដែលបណ្តាលមកពីការលុបចោល ការប្រែប្រួល ឬការខូចទ្រង់ទ្រាយនៃរចនាសម្ព័ន្ធដើម និងការបាត់បង់ដោយសារការផ្អាកអាជីវកម្មដែលបង្កឡើងដោយសារការបាត់បង់ ឬការខូចខាតនោះ ។ ទោះបីជាមានការលើកលែងនេះក៏ដោយការបាត់បង់ ឬការខូចខាតទិន្នន័យ ឬកម្មវិធីកុំព្យូទ័រ ដែលជាលទ្ធផលដោយផ្ទាល់នៃការខូចខាតផ្នែករូបវន្តដែលមានការធានារ៉ាប់រងដល់លក្ខណៈសំខាន់នៃទ្រព្យសម្បត្តិត្រូវបានធ្វើសំណង។

(ខ) ការបាត់បង់ ឬការខូចខាតដែលបណ្តាលមកពីភាពអន់ថយផ្នែកមុខងារ ភាពអាចរកបានកម្រិតនៃការប្រើប្រាស់ ឬភាពអាចបើកមើលបាននៃទិន្នន័យ ឬកម្មវិធីកុំព្យូទ័រ និងការខាតបង់ដោយសារការផ្អាកអាជីវកម្ម ដែលបង្កឡើងដោយសារការបាត់បង់ ឬការខូចខាតនោះ។

(ង) **បដិលេខស្ដីអំពី ករណីលើកលែងសកម្មភាពភេរវកម្ម**

ការធានារ៉ាប់រងដែលផ្តល់ជូន យោងតាមកិច្ចសន្យាធានារ៉ាប់រងនេះមិនអនុវត្តចំពោះចំណុចខាងក្រោម:

ការបាត់បង់ សោហ៊ុយ ឬថ្លៃចំណាយដែលកើតចេញពី ឬទាក់ទិននឹង ទោះបីជាដោយផ្ទាល់ ឬដោយប្រយោលក៏ដោយ "សកម្មភាពភេរវកម្ម" ដូចបានកំណត់និយមន័យនៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ។ ការលើកលែងនេះនឹងយកមកអនុវត្តដោយមិនគិតអំពីមូលហេតុ ឬព្រឹត្តិការណ៍ផ្សេងទៀតដែលរួមចំណែកក្នុងពេលដំណាលគ្នា ឬនៅក្នុងដំណាក់កាលណាមួយធ្វើអោយមានការបាត់បង់ សោហ៊ុយ ឬថ្លៃចំណាយ។

សម្រាប់គោលបំណងនៃការលើកលែងនេះ:

ក. "សកម្មភាពភេរវកម្ម" សំដៅដល់សកម្មភាពដោយចេតនាខុសច្បាប់ដែល:

១. ត្រូវបានប្រកាសដោយមន្ត្រីរដ្ឋាភិបាលដែលមានសមត្ថកិច្ចថាជាអំពើភេរវកម្ម ឬពាក់ព័ន្ធនឹងអំពើភេរវកម្ម សកម្មភាពរបស់ភេរវករ ឬសកម្មភាពភេរវកម្ម ឬ

២. រួមបញ្ចូល ពាក់ព័ន្ធ ឬទាក់ទិននឹងការប្រើប្រាស់ ឬការគំរាមប្រើប្រាស់កម្លាំង អំពើហិង្សា ឬការបង្កគ្រោះថ្នាក់ ប្រឆាំងនឹង បុគ្គលណាម្នាក់ ទ្រព្យសម្បត្តិរូបី ឬអរូបី បរិស្ថាន ឬធនធានធម្មជាតិ នៅពេលដែលសកម្មភាពត្រូវបានព្រាងទុកទាំងស្រុង ឬមួយផ្នែក ដើម្បី

(ក) លើកស្ទួយ ឬបន្តមូលហេតុ ឬកម្មវត្ថុនយោបាយ មនោគមវិជ្ជា ទស្សនវិជ្ជា ពូជសាសន៍ ជាតិពន្ធ សង្គម ឬសាសនា ឬអង្គការ សមាគម ឬក្រុមណាមួយដែលទាក់ទងជាមួយនឹងឧក្រិដ្ឋជន

(ខ) ជះឥទ្ធិពល រំខាន ឬជ្រៀតជ្រែកក្នុងប្រតិបត្តិការ សកម្មភាព ឬគោលនយោបាយរបស់រដ្ឋាភិបាល

(គ) សម្លុត បង្ខំ ឬបំភ័យសាធារណជនទូទៅ ឬផ្នែកណាមួយនៃសាធារណជន ឬ

(ឃ) រំខាន ឬជ្រៀតជ្រែកក្នុងសេដ្ឋកិច្ចជាតិ ឬផ្នែកណាមួយនៃសេដ្ឋកិច្ចជាតិ ឬ

៣. រួមបញ្ចូល ពាក់ព័ន្ធ ឬទាក់ទងទាំងស្រុង ឬមួយផ្នែកជាមួយនឹងសកម្មភាពណាមួយខាងក្រោមនេះ ឬការគំរាមបង្ក:

(ក) ការប្លន់យន្តហោះ ឬការបំផ្លាញមធ្យោបាយដឹកជញ្ជូន ឬយានដឹកជញ្ជូនគ្រប់ប្រភេទរួមមានជាអាទិ៍ យានអវកាស ផ្កាយរណប យន្តហោះ រថភ្លើង កប៉ាល់ ឬយានយន្ត

(ខ) ការចាប់ចំណាប់ខ្មាំង ឬចាប់ជំរិត

(គ) ការប្រើប្រាស់សារធាតុ ឬសញ្ញារុធជីវសាស្ត្រ គីមី វិទ្យុសកម្ម ឬនុយក្លេអ៊ែរ

(ឃ) ការប្រើប្រាស់គ្រាប់បែក អាវុធបង្កអោយអគ្គិភ័យ គ្រឿងផ្ទុះ ឬកាំភ្លើងដៃ

(ង) ការជ្រៀតជ្រែក ឬការរំខានដល់សេវា និងប្រព័ន្ធសាធារណៈមូលដ្ឋាន ឬដល់សេវា និងប្រព័ន្ធ អាជីវកម្មមូលដ្ឋាន រួមមានជាអាទិ៍ សេវា ឬប្រព័ន្ធដូចតទៅ : អគ្គិសនី ឧស្ម័នធម្មជាតិ ថាមពល ប្រៃសណីយ៍ ទំនាក់ទំនង ទូរគមនាគមន៍ ព័ត៌មាន ការដឹកជញ្ជូនសាធារណៈ ទឹកឥន្ទនៈ ទឹកស្អុយ ឬការប្រមូលសំរាម

(ច) ការបង្ករបួស ឬការធ្វើឃាតមន្ត្រីរដ្ឋាភិបាល ឬបុគ្គលិករដ្ឋាភិបាលណាម្នាក់ ដែលត្រូវបានបោះឆ្នោត ឬជ្រើសតាំង

(ឆ) ការរឹបអូស ការរាំងស្ទះ ការជ្រៀតជ្រែក ការរំខាន ឬការបំផ្លាញអគាររដ្ឋាភិបាល ស្ថាប័ន ពិធី ព្រឹត្តិការណ៍ ទ្រព្យសម្បត្តិរូបី និងអរូបី ឬទ្រព្យសម្បត្តិផ្សេងទៀត ឬ

(ជ) ការរឹបអូស ការរាំងស្ទះ ការជ្រៀតជ្រែក ការរំខាន ឬការបំផ្លាញផ្លូវក្រោមដីថ្នល់ ផ្លូវ យន្តបថ ឬ កន្លែងដឹកជញ្ជូនសាធារណៈផ្សេងទៀត។

ខ. សកម្មភាពណាមួយដែលមានរៀបរាប់នៅក្នុងផ្នែក ក (៣) ខាងលើ ត្រូវចាត់ទុកជាសកម្មភាពរបស់ភេរវករ លើកលែងតែបុគ្គលដែលត្រូវបានធានារ៉ាប់រង អាចបង្ហាញដោយគ្មានការសង្ស័យចំពោះក្រុមហ៊ុនថា សកម្មភាព ឬការគំរាមកំហែងខាងលើនេះត្រូវបានជំរុញទាំងស្រុងដោយគោលបំណងផ្ទាល់ខ្លួនរបស់ឧក្រិដ្ឋជនដែលមិនទាក់ទងទាំងស្រុង ឬមួយផ្នែកចំពោះការប៉ុនប៉ងណាមួយក្នុងការ

១. លើកស្ទួយ ឬបន្តមូលហេតុ ឬវត្ថុបំណងនយោបាយ មនោគមវិជ្ជា ទស្សនវិជ្ជា ពូជសាសន៍ ជាតិពន្ធុ សង្គម ឬសាសនារបស់ឧក្រិដ្ឋជន ឬអង្គការ សមាគម ឬក្រុមណាមួយដែលទាក់ទងជាមួយឧក្រិដ្ឋជន

២. ជះឥទ្ធិពល រំខាន ឬជ្រៀតជ្រែកក្នុងប្រតិបត្តិការ សកម្មភាព ឬគោលនយោបាយរបស់រដ្ឋាភិបាល

៣. សម្លុត បង្ខំ ឬបំភ័យសាធារណជនទូទៅ ឬផ្នែកណាមួយនៃសាធារណជន ឬ

៤. រំខាន ឬជ្រៀតជ្រែកក្នុងសេដ្ឋកិច្ចជាតិ ឬផ្នែកណាមួយនៃសេដ្ឋកិច្ចជាតិ

(ច) **ខ ចែង ស្តីអំពីករណីលើកលែងចំពោះជំងឺស្លូត**

ភាគីទាំងពីរបានយល់ និងព្រមព្រៀងថាកិច្ចសន្យាធានារ៉ាប់រងនេះមិនអនុវត្តចំពោះ និងផ្តល់សំណងលើការទទួលខុសត្រូវ ជាក់ស្តែង ឬសន្មតណាមួយសម្រាប់ការទាមទារមួយ ឬច្រើនទាក់ទិននឹងការបាត់បង់មួយ ឬច្រើន ដោយផ្ទាល់ ឬដោយប្រយោលដែលកើតចេញពី ឬបណ្តាលមកពី ឬផលវិបាកនៃជំងឺស្លូត ឬជំងឺផ្លូវដង្ហើម ទោះបីជាក្នុងទម្រង់ ឬបរិមាណណាក៏ដោយ។

## ការបកស្រាយ

សម្រាប់គោលបំណងនៃកិច្ចសន្យាធានារ៉ាប់រងនេះ

(ក) សំណើសំដៅដល់ទម្រង់សំណើ ឬសេចក្តីប្រកាសដែលមានចុះហត្ថលេខា និងព័ត៌មានណាមួយដែលផ្តល់ដោយ ឬ ក្នុងនាមបុគ្គលដែលត្រូវបានធានារ៉ាប់រងបន្ថែមទៅលើ ឬជំនួសឱ្យទម្រង់សំណើ ឬសេចក្តីប្រកាសនោះ

(ខ) ពាក្យ "យានយន្ត" រួមបញ្ចូលនូវប្រភេទណាមួយនៃម៉ាស៊ីននៅលើកង់ ឬច្រវាក់

(គ) ពាក្យ "កប៉ាល់ទឹក ឬយន្តហោះ" សំដៅដល់កប៉ាល់ទឹក យន្តហោះ ឬវត្ថុអ្វីមួយដែលបង្កើតឡើង ឬគ្រោងដើម្បីបណ្តែតលើ ឬក្នុង ឬធ្វើដំណើរលើ ឬឆ្លងកាត់ទឹក ឬអាកាស

(ឃ) ពាក្យ "របួសលើរាងកាយ" រួមបញ្ចូលការស្លាប់ ជំងឺ និងរោគផ្សេងៗ

(ង) ពាក្យ "ការខូចខាត" រួមបញ្ចូលការបាត់បង់

(ច) ពាក្យ "ទ្រព្យសម្បត្តិ" សំដៅដល់តែទ្រព្យសម្បត្តិជាសម្ភារប៉ុណ្ណោះ

## ដែនកំណត់នៃសំណង

១. ការទទួលខុសត្រូវរបស់ក្រុមហ៊ុនយោងតាមកិច្ចសន្យាធានារ៉ាប់រងនេះ គឺចំពោះរាល់សំណងដែលត្រូវបង់រួមមានការខូចខាត និងសោហ៊ុយ និងថ្លៃចំណាយផ្សេងៗរបស់អ្នកប្តឹងទាមទារសំណង :

(ក) ដល់អ្នកទាមទារណាមួយ ឬអ្នកទាមទារជាច្រើនទាក់ទិននឹង ឬកើតចេញពីហេតុការណ៍ណាមួយ ឬ ហេតុការណ៍ជាច្រើន ដែលកើតចេញពី ឬបង្កឡើងពីប្រភព ឬដើមហេតុដំបូងតែមួយ មិនត្រូវលើសពីដែនកំណត់នៃការធ្វើសំណងដែលមានចែងនៅក្នុងតារាងឧបសម្ព័ន្ធសម្រាប់គ្រោះថ្នាក់និមួយៗឡើយ

(ខ) ទាក់ទិននឹងរាល់របួសស្នាមលើរាងកាយ និងការបាត់បង់ដែលទទួលរងក្នុងអំឡុងពេលនៃការធ្វើសំណងណាមួយមិនត្រូវហួសពីដែនកំណត់នៃការធ្វើសំណងដែលមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ សម្រាប់រយៈពេលធានារ៉ាប់រងណាមួយឡើយ

២. លើសពីនេះទៀត ក្រុមហ៊ុននឹងបង់រាល់សោហ៊ុយ និងថ្លៃចំណាយផ្សេងៗដែលបានកើតឡើង ដោយមានការយល់ព្រមជាលាយលក្ខណ៍អក្សររបស់ខ្លួន លុំកណាការធ្វើសំណងទាំងនោះ ត្រូវស្ថិតក្រោមដែនកំណត់នៃការធ្វើសំណងដែលមានចែងក្នុងតារាងឧបសម្ព័ន្ធជានិច្ច។

៣. ក្រុមហ៊ុននឹងទទួលខុសត្រូវចំពោះការខូចខាត ឬសំណង និងសោហ៊ុយនិងថ្លៃចំណាយជម្រះក្តីពាក់ព័ន្ធ ដែលត្រូវបង់យោងតាម ៦ ចែង និងលក្ខខណ្ឌនៃកិច្ចសន្យាធានារ៉ាប់រងនេះ តែក្នុងកម្រិតដែលការបូកសរុបនៃទឹកប្រាក់ទាំងនោះ ដែលកើតចេញពីហេតុការណ៍មួយ លើសពីចំនួនទឹកប្រាក់ដែលត្រូវចូលរួមចំណែកធ្វើសំណង ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ។ បុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវទទួលខុសត្រូវដោយខ្លួនឯងចំពោះការខូចខាត និងសំណងព្រមទាំងសោហ៊ុយ និងថ្លៃចំណាយពាក់ព័ន្ធរហូតដល់ចំនួនទឹកប្រាក់ដែលត្រូវចូលរួមចំណែកធ្វើសំណងសម្រាប់ហេតុការណ៍ដែលកើតឡើងនិមួយៗ។

ដោយហេតុថា ការទទួលខុសត្រូវរបស់ក្រុមហ៊ុនទាក់ទិននឹងចំណុច (១) និង (២) ខាងលើមិនត្រូវលើសពីដែនដំណត់នៃការធ្វើសំណងដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ។

## លក្ខខណ្ឌ

កិច្ចសន្យាធានារ៉ាប់រងនេះ និងតារាងឧបសម្ព័ន្ធត្រូវអានជាមួយគ្នាជាកិច្ចសន្យាតែមួយហើយពាក្យ និងវាក្យសព្ទដែលមានអត្ថន័យជាក់លាក់ស្ថិត នៅក្នុងផ្នែកណាមួយនៃកិច្ចសន្យានេះ ឬតារាងឧសម្ព័ន្ធ ត្រូវមានអត្ថន័យបែបនោះ ទោះបីជាប្រើនៅកន្លែងណាក៏ដោយ

១. ការធានារ៉ាប់រងនេះនឹងត្រូវចាប់ផ្តើម នៅពេលដែលបុព្វលាភធានារ៉ាប់រងត្រូវបានបង់យ៉ាងជាក់ស្តែងដល់ និងទទួលដោយក្រុមហ៊ុនហើយលិខិតទទួលយកជាផ្លូវការ ឬកិច្ចសន្យាធានារ៉ាប់រងរបស់ក្រុមហ៊ុនត្រូវបានចេញ ។ គ្មានការបង់ប្រាក់ណាមួយទាក់ទិន នឹងបុព្វលាភធានារ៉ាប់រង ត្រូវចាត់ទុកថាជាការបង់ប្រាក់ទៅអោយក្រុមហ៊ុនឡើយ លើកលែងតែទម្រង់វិក្កយបត្រពោះពុម្ពដែលចុះហត្ថលេខាដោយមន្ត្រី ឬតំណាងមានការអនុញ្ញាត ត្រឹមត្រូវរបស់ក្រុមហ៊ុន ត្រូវបានចេញ។

២. បុគ្គលដែលត្រូវបានធានារ៉ាប់រង ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ក្រុមហ៊ុនជាបន្ទាន់ អំពីគ្រោះថ្នាក់ ឬ ការទាមទារសំណង ឬដំណើរការក្តីណាមួយ នៅពេលបុគ្គលដែលត្រូវបានធានារ៉ាប់រង ឬតំណាងរបស់ខ្លួនបានដឹង អំពីគ្រោះថ្នាក់ ឬការទាមទារ ឬដំណើរការក្តីទាំងនោះ។

៣. ប្រសិនបើគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីក្រុមហ៊ុនទេ បុគ្គលដែលត្រូវបានធានារ៉ាប់រង មិនត្រូវបដិសេធការទទួលខុស ត្រូវចរចា ឬទទួលយក ផ្ដល់សន្យា ឬបង់ប្រាក់ទាក់ទិននឹងគ្រោះថ្នាក់ ឬការទាមទារណាមួយឡើយហើយក្រុមហ៊ុនត្រូវមានសិទ្ធិប្រសិនបើខ្លួនត្រូវការដូច្នេះ ដើម្បីទទួលយក និងអនុវត្តក្នុងនាមបុគ្គលដែលត្រូវបានធានារ៉ាប់រងនូវការការពារការទាមទារណាមួយ ឬដើម្បីធ្វើការប្ដឹងក្នុងនាមបុគ្គលដែលត្រូវបានធានារ៉ាប់រងក្រោមចំណាយផ្ទាល់ខ្លួន និងដើម្បីអត្ថប្រយោជន៍ផ្ទាល់ខ្លួន ចំពោះរាល់ការទាមទារសំណង ឬការសងការខូចខាត ឬសំណងផ្សេងទៀតប្រឆាំងនឹងបុគ្គលណាមួយ ហើយត្រូវមានឆន្ទានុសិទ្ធិពេញលេញនៅក្នុងការអនុវត្តដំណើរការក្ដី និងនៅក្នុងការដោះស្រាយការទាមទារណាមួយហើយបុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវផ្ដល់ព័ត៌មាន និងជំនួយទាំងអស់តាមការស្នើសុំរបស់ក្រុមហ៊ុន។

៤. ក្នុងករណីមានគ្រោះថ្នាក់ ក្រុមហ៊ុនអាចបង់ទៅអោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ត្រឹមដែនកំណត់នៃការធ្វើសំណង ចំពោះគ្រោះថ្នាក់ណាមួយ (ប៉ុន្តែក្នុងករណីនេះ ត្រូវដកចេញនូវទឹកប្រាក់ណាមួយដែលបានបង់ជាសំណងរួច) ឬនូវទឹកប្រាក់ដែលទាបជាងនេះដែលការទាមទារសំណងមួយឬច្រើនកើតចេញពីគ្រោះថ្នាក់តែមួយ អាចត្រូវបានដោះស្រាយហើយ ក្រុមហ៊ុនមិនទទួលខុសត្រូវផ្សេងទៀតនៅពេលក្រោយទាក់ទិននឹងគ្រោះថ្នាក់នេះទេ លើកលែងតែចំពោះការបង់សោហ៊ុយ និងថ្លៃចំណាយផ្សេងៗ លើការជម្រះក្ដីយោងតាមចំណុច (ខ) នៅត្រង់ទំព័រទី១ នៃកិច្ចសន្យាធានារ៉ាប់រងនេះបានកើតឡើងមុនកាលបរិច្ឆេទធ្វើសំណងតាមដែនកំណត់នៃសំណង ឬចំនួនទឹកប្រាក់ដែលតិចជាងគេ។

៥. ប្រសិនបើបុព្វលាភធានារ៉ាប់រងសម្រាប់កិច្ចសន្យាធានារ៉ាប់រងនេះ ត្រូវបានគណនាតាមតារាងប៉ាន់ស្មានតម្លៃ ដែលផ្ដល់ដោយបុគ្គលដែលត្រូវបានធានារ៉ាប់រងបុគ្គលនោះត្រូវរក្សាទុកនូវឯកសារអោយបានត្រឹមត្រូវដែលឯកសារនោះកត់ត្រាអំពីចំណុចលម្អិតទាំងអស់ពាក់ព័ន្ធនឹងបុព្វលាភធានារ៉ាប់រងហើយនៅគ្រប់ពេលទាំងអស់ត្រូវអនុញ្ញាតអោយក្រុមហ៊ុនធ្វើការពិនិត្យនូវឯកសារទាំងនោះ។ ក្នុងរយៈពេលមួយខែបន្ទាប់ពីកាលបរិច្ឆេទផុតកំណត់រយៈពេលធានារ៉ាប់រងនីមួយៗ បុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវផ្ដល់ដល់ក្រុមហ៊ុននូវរាល់ចំណុចលម្អិត និងព័ត៌មានតាមការស្នើសុំរបស់ក្រុមហ៊ុន។ បុព្វលាភធានារ៉ាប់រងសម្រាប់រយៈពេលនោះអាចត្រូវកែសម្រួលហើយភាពខុសគ្នាត្រូវបង់ដោយ ឬផ្ដល់ដល់បុគ្គលដែលត្រូវបានធានារ៉ាប់រងទៅតាមករណីជាក់ស្ដែង។

៦. ប្រសិនបើនៅពេលមានការទាមទារណាមួយកើតឡើងយោងតាមកិច្ចសន្យាធានារ៉ាប់រងនេះ មានការធានារ៉ាប់រងណាមួយផ្សេងទៀតដែលធានាលើហានិភ័យតែមួយ ឬផ្នែកណាមួយនៃហានិភ័យនេះ ក្រុមហ៊ុនមិនទទួលខុសត្រូវចំពោះសំណងដែលច្រើនជាង សមាមាត្ររបស់ខ្លួនឡើយ។

៧. ប្រសិនបើនៅពេលណាមួយ ឬម្ដងម្កាលមានការផ្លាស់ប្ដូរណាមួយកើតឡើងយ៉ាងជាក់ស្ដែង ដែលធ្វើអោយប្រែប្រួលហេតុការណ៍ដែលបានកើតឡើងនៅកាលបរិច្ឆេទនៃសំណើ បុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ក្រុមហ៊ុនក្នុងរយៈពេលប្រាំពីរ (៧)ថ្ងៃ ហើយត្រូវបង់ថ្លៃបុព្វលាភធានារ៉ាប់រងបន្ថែមតាមការស្នើសុំរបស់ក្រុមហ៊ុន។ ប៉ុន្តែរហូតដល់ពេលក្រុមហ៊ុនបានព្រមព្រៀង ជាលាយលក្ខណ៍អក្សរក្នុងការទទួលយកនូវការទទួលខុសត្រូវចំពោះហានិភ័យដែលប្រែប្រួលនោះ បើមិនដូច្នោះទេ ក្រុមហ៊ុនមិនទទួលខុសត្រូវទាក់ទិននឹងរបួសស្នាម ឬជំងឺ ឬការបាត់បង់ ឬការខូចខាត ដែលកើតឡើងជាមួយគ្នា ឬមួយផ្នែក ចំពោះការប្រែប្រួល ឬការផ្លាស់ប្ដូរនោះឡើយ។

៨. ការធានារ៉ាប់រងនេះអាចត្រូវបានបញ្ឈប់នៅពេលណាមួយតាមសំណើរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រងដោយជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ១០ ថ្ងៃ ក្នុងករណីនេះក្រុមហ៊ុននឹងបង្វិលសងជូនបុគ្គលដែលត្រូវបានធានារ៉ាប់រងវិញចំនួនកៅសិបភាគរយ (៩០%) នៃបុព្វលាភធានារ៉ាប់រងដែលនៅសល់សម្រាប់រយៈពេលដែលនៅមានសុពលភាព គិតចាប់ពីថ្ងៃសុំបញ្ឈប់នៃកិច្ចសន្យាធានារ៉ាប់រងនេះដោយក្នុងលក្ខខណ្ឌថាពុំមានបណ្ដឹងទាមទារសំណងណាមួយកើតឡើងក្នុងអំឡុងពេលនៃការធានារ៉ាប់រងនេះទេ។ កិច្ចសន្យាធានារ៉ាប់រងនេះក៏អាចត្រូវបានបញ្ឈប់ផងដែរតាមជម្រើសរបស់ក្រុមហ៊ុនដោយធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល១០ថ្ងៃ ជាមុនទៅកាន់អាសយដ្ឋានដែលគេស្គាល់ចុងក្រោយរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រងក្នុងករណីនេះលោកអ្នកមានសិទ្ធិទទួលបានការបង្វិលសងបុព្វលាភមកវិញតាមសមាមាត្រនៃបុព្វលាភសម្រាប់រយៈពេលដែលនៅមានសុពលភាពគិតចាប់ពីថ្ងៃសុំបញ្ឈប់ការធានារ៉ាប់រង។ រាល់ការសុំបញ្ឈប់ការធានារ៉ាប់រងលោកអ្នកនឹងមិនត្រូវបានបង្វិលសងនូវបុព្វលាភធានារ៉ាប់រងឡើយប្រសិនបើបុព្វលាភនោះត្រូវបានបង់ក្នុងកម្រិតអប្បបរមា។

៩. បុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវធ្វើការប្រុងប្រយ័ត្នយ៉ាងសមហេតុផលថា មានតែបុគ្គលិកទៀងទាត់ម៉ត់ចត់ និងមានសមត្ថភាពប៉ុណ្ណោះត្រូវបានទទួលអោយធ្វើការ ហើយរាល់អគារ ផ្លូវដើរ ការងារ រោងចក្រ គ្រឿងម៉ាស៊ីន គ្រឿងសង្ហារិម និងសម្ភារជាប់នឹងអគារមានលក្ខណៈមាំ និងមានសណ្ដាប់ធ្នាប់ល្អហើយសមស្របសម្រាប់គោលបំណងដែលវាត្រូវបានប្រើប្រាស់ និងថារាល់លក្ខខណ្ឌតម្រូវដោយច្បាប់ និងរាល់ប្រកាស និងបទបញ្ជាដែលដាក់ចេញដោយអាជ្ញាធរសាធារណៈត្រូវបានគោរព និងប្រតិបត្តិតាមយ៉ាងត្រឹមត្រូវ។ នៅពេលមានភាពខ្វះចន្លោះត្រូវបានកត់សម្គាល់បុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវចាត់វិធានការជាបន្ទាន់ ដើម្បីធ្វើការកែលំអឡើងវិញ និងត្រូវចាត់វិធានការការពារបណ្ដោះអាសន្នជាមុនដើម្បីបង្ការគ្រោះថ្នាក់តាមដែលស្ថានការណ៍តម្រូវ ប៉ុន្តែតាមការអនុវត្តជាក់ស្ដែង គ្មានការកែប្រែ ឬការជួសជុលបន្ទាប់ពីមានហេតុការណ៍ណាមួយត្រូវបានធ្វើសំណងដោយកិច្ចសន្យាធានារ៉ាប់រងនេះត្រូវបានអនុញ្ញាតដោយគ្មានការយល់ព្រមពីក្រុមហ៊ុនឡើយ រហូតដល់ពេលក្រុមហ៊ុនមានឱកាសដើម្បីធ្វើការស៊ើបអង្កេតជាមុន។ នៅក្នុងពេលវេលាដ៏សមរម្យណាមួយ ក្រុមហ៊ុនមានសិទ្ធិចូលដោយសេរីដើម្បីពិនិត្យមើលទ្រព្យសម្បត្តិ។ ក្នុងករណីអ្នកពិនិត្យរបស់ក្រុមហ៊ុនមើលឃើញពីភាពខ្វះចន្លោះ ឬគ្រោះថ្នាក់ណាមួយក្រុមហ៊ុនអាចជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បុគ្គលដែលត្រូវបានធានារ៉ាប់រង ហើយរាល់ការទទួលខុសត្រូវរបស់ក្រុមហ៊ុនដែលពាក់ព័ន្ធនឹងឬកើតឡើងពីភាពខ្វះចន្លោះទាំងនោះត្រូវបានផ្អាករហូតដល់ពេលភាពខ្វះចន្លោះទាំងនោះត្រូវបានដោះស្រាយ ឬយកចេញតាមតម្រូវចិត្តរបស់ក្រុមហ៊ុន។

១០. រាល់វិវាទដែលកើតចេញពីកិច្ចសន្យាធានារ៉ាប់រងនេះត្រូវបញ្ជូនទៅដោះស្រាយដោយមជ្ឈត្តករមួយរូបដែលតែងតាំងឡើងជាលាយលក្ខណ៍អក្សរដោយភាគីវិវាទ ឬប្រសិនបើពួកគេមិនអាចព្រមព្រៀងគ្នាយកមជ្ឈត្តករតែមួយរូបដែលត្រូវបានតែងតាំងជាលាយលក្ខណ៍អក្សរដោយភាគីនីមួយៗក្នុងរយៈពេលមួយខែប្រតិទិនបន្ទាប់ពីត្រូវបានតម្រូវជាលាយលក្ខណ៍អក្សរអោយធ្វើដូច្នេះដោយភាគីនីមួយៗ ឬក្នុងករណីក្រុមមជ្ឈត្តករមិនព្រមព្រៀងគ្នាយកមជ្ឈត្តករវិនិច្ឆ័យមួយរូបដែលត្រូវបានតែងតាំងជាលាយលក្ខណ៍អក្សរដោយក្រុមមជ្ឈត្តករមុនពេលចាប់ផ្តើមបញ្ជូន។ មជ្ឈត្តករវិនិច្ឆ័យត្រូវអង្គុយជាមួយក្រុមមជ្ឈត្តករ និងធ្វើជាអធិបតីក្នុងកិច្ចប្រជុំរបស់ពួកគេ ហើយការចេញមជ្ឈត្តវិនិច្ឆ័យគឺជាលក្ខខណ្ឌជាមុននៃសិទ្ធិប្តឹងណាមួយប្រឆាំងនឹងក្រុមហ៊ុន។ ប្រសិនក្រុមហ៊ុនបោះបង់ការទទួលខុសត្រូវចំពោះបុគ្គលដែលត្រូវបានធានារ៉ាប់រងចំពោះការទាមទារណាមួយ ហើយការទាមទារនោះមិនត្រូវបានធ្វើឡើង ក្នុងរយៈពេលដប់ពីរ (១២) ខែប្រតិទិនចាប់ពីកាលបរិច្ឆេទនៃការបោះបង់នេះ ត្រូវបានបញ្ជូនទៅដោះស្រាយដោយមជ្ឈត្តករយោងតាមបញ្ញត្តិដែលមានចែងនៅក្នុងកិច្ចសន្យានេះ នោះការទាមទារត្រូវចាត់ទុកថាត្រូវបានបោះបង់សម្រាប់គ្រប់គោលបំណងទាំងអស់ហើយមិនអាចទាមទារសំណងនៅពេលក្រោយយោងតាមកិច្ចសន្យានេះបានឡើយ។

១១. ការគោរព និងអនុវត្តតាមយ៉ាងត្រឹមត្រូវនូវ ខចែង បញ្ញត្តិ លក្ខខណ្ឌ និងបដិលេខនៃកិច្ចសន្យាធានារ៉ាប់រងនេះដោយបុគ្គលដែលត្រូវបានធានារ៉ាប់រងក្នុងកម្រិតដែលវាមានការពាក់ព័ន្ធនឹងចំណុចដែលខ្លួនត្រូវធ្វើ ឬគោរពតាមហើយភាពពិតប្រាកដនៃសេចក្តីប្រកាសអះអាង និងចម្លើយនៅក្នុងសំណើដែលបានលើកឡើង គឺជាលក្ខខណ្ឌជាមុននៃការទទួលខុសត្រូវរបស់ក្រុមហ៊ុនក្នុងការបង់សំណងយោងតាមកិច្ចសន្យាធានារ៉ាបរងនេះ។

១២. ក្រុមហ៊ុនមិនទទួលខុសត្រូវក្នុងការធ្វើ :

(ក) សំណងសម្រាប់ការខូចខាតទាក់ទិននឹងសាលក្រមដែលមិនមែនចេញ ឬទទួលបានពីតុលាការដែលមានយុត្តាធិការនៅក្នុងប្រទេសកម្ពុជា

(ខ) សោហ៊ុយ និងថ្លៃចំហាយលើការជម្រះក្តីដែលអាចទទួលបានដោយអ្នកទាមទារសំណងណាមួយពីបុគ្គលដែលត្រូវបានធានារ៉ាប់រងដែលមិនកើតឡើង និងមិនអាចទទួលបានមកវិញនៅក្នុងប្រទេសកម្ពុជា

១៣. ការគ្រប់គ្រងដោយច្បាប់

កិច្ចសន្យាធានារ៉ាប់រងនេះត្រូវបកស្រាយហើយរាល់ទំនាស់ទាក់ទិននឹងកិច្ចសន្យាធានារ៉ាប់រងនេះ ត្រូវកំណត់ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

១៤. លក្ខខណ្ឌធានាចំពោះបុព្វលាភធានារ៉ាប់រង

វាជាលក្ខខណ្ឌមូលដ្ឋាន និងពិសេសបំផុតនៃកិច្ចសន្យាធានារ៉ាប់រងនេះដែលបុព្វលាភធានារ៉ាប់រងត្រូវតែបង់ និងទទួលបានដោយក្រុមហ៊ុនក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ចាប់ពីកាលបរិច្ឆេទចាប់ផ្តើមកិច្ចសន្យាធានារ៉ាប់រងនេះ /បដិលេខ/ វិញ្ញាបនបត្របន្តការធានារ៉ាប់រង។ ប្រសិនបើលក្ខខណ្ឌនេះមិនត្រូវបានគោរពទេនោះកិច្ចសន្យានេះត្រូវបានបញ្ឈប់ដោយស្វ័យប្រវត្តិហើយ ក្រុមហ៊ុនមានសិទ្ធិទទួលបានបុព្វលាភធានារ៉ាប់រងតាមសមាមាត្រសម្រាប់រយៈពេលដែលខ្លួនស្ថិតក្នុងហានិភ័យ។ ប្រសិនបើបុព្វលាភធានារ៉ាប់រងដែលត្រូវបង់ស្របតាមការធានានេះត្រូវបានទទួលដោយភ្នាក់ងារមានការអនុញ្ញាតរបស់ក្រុមហ៊ុនប្រាក់នេះត្រូវចាត់ទុកថាបានទទួលដោយក្រុមហ៊ុនសម្រាប់គោលបំណងនៃការធានានេះហើយកាតព្វកិច្ចក្នុងការបង្ហាញថាបុព្វលាភធានារ៉ាប់រងដែលត្រូវបង់ត្រូវបានទទួលដោយបុគ្គលម្នាក់ រួមទាំងភ្នាក់ងារធានារ៉ាប់រងដែលមិនត្រូវបានអនុញ្ញាតអោយទទួលបុព្វលាភធានារ៉ាប់រងនោះ ត្រូវធ្លាក់ទៅលើក្រុមហ៊ុន។ រាល់លក្ខខណ្ឌ និង ខ ចែងទាំងអស់ត្រូវផ្អែកលើកិច្ចសន្យាធានារ៉ាប់រងនេះ។

១៥. ខ ចែងស្តីអំពីការដាក់កំហិតទណ្ឌកម្ម និងករណីលើកលែង (LMA 3100)

គ្មានក្រុមធានារ៉ាប់រងណាមួយអាចផ្តល់ការធានារ៉ាប់រង និងទទួលខុសត្រូវចំពោះការផ្តល់ប្រាក់សំណងណាមួយ ឬផ្តល់អត្ថប្រយោជន៍ណាមួយដែលស្ថិតនៅក្នុងដែនកំណត់នៃបុរេលក្ខខណ្ឌនៃការធានារ៉ាប់រងនោះបានឡើយដែលការផ្តល់សំណង ឬអត្ថប្រយោជន៍ទាំងនោះធ្វើអោយក្រុមហ៊ុនធានារ៉ាប់រងប្រឈមមុខនឹងការដាក់ទណ្ឌកម្មណាមួយ ការហាមឃាត់ ឬការដាក់កម្រិតដែលស្ថិតនៅក្រោមសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ឬការដាក់ទណ្ឌកម្មផ្នែកសេដ្ឋកិច្ច ឬពាណិជ្ជកម្ម ច្បាប់ ឬនិយតកម្មរបស់សហគមន៍អឺរ៉ុប ចក្រភពអង់គ្លេស ឬសហរដ្ឋអាមេរិក។